**ប្រការ៣.~** ក្រុមការងារអាស៊ានត្រូវបានទទួលភារកិច្ចដូចក្នុងប្រការ ២ បន្ថែមពីលើភារកិច្ចរបស់សមាជិកនៃក្រុមនេះដែលកំពុងមានបច្ចុប្បន្ន ។

**ប្រការ ៤.~** ក្រុមការងារនេះមានសិទ្ធិអញ្ជើញមន្ត្រី និងភ្នាក់ងារគយក្នុងអង្គភាព , ការិយាល័យ , សាខាទាំងអស់ដែលមានការពាក់ព័ន្ធអោយចូលរួមធ្វើការងារ ការរៀបចំឯកសារការប្រជុំពិភាក្សាតាមការជាក់ស្តែង ។

**ប្រការ ៥.~** នាយកខុទ្ទកាល័យ ប្រធាន មន្ទីរ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធានក្រុមការងារអាស៊ាន នាយកទីចាត់ការគយ និង រដ្ឋាករ និងសាម៉ីខ្លួនត្រូវទទួលអនុវត្តតាមប្រកាសនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ហត្ថលេខា និង ត្រា

**គាត ឈន់**

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ១៩៩៦

**ប្រកាស លេខ : ២៥៧ ប្រក.សហវ.គរ**

**ស្តីពីការគ្រប់គ្រងលើទំនិញនាំចូល**

* * *

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និង នាយករដ្ឋមន្ត្រីទី២ នៃរាជរដ្ឋាភិបាល

- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យ នស ១០៩៤ / ៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម នស.រកម ០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦
- បានឃើញច្បាប់ស្តីពីពន្ធលើទំនិញនាំចេញនិង នាំចូល ដែលប្រកាសអោយប្រើដោយក្រឹត្យលេខ ៥៧ ក្រ ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ១៩៨៩
- បានឃើញប្រកាសលេខ ១២៥ ប្រក.សហវ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចុះថ្ងៃទី ២៥ ខែសីហា ឆ្នាំ ១៩៩៤ ស្តីពីឃ្លាំងដែលគ្រប់គ្រងដោយគយនិងទីលានបញ្ចេញទំនិញពីគយ និងរដ្ឋាករ
- យោងការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

**សំរេច**

**ប្រការ ១.~** កំណត់រយៈកាលសំចតនៃទំនិញក្នុងឃ្លាំងឬទីលានបញ្ចេញទំនិញពីគយគឺមាន ÷

- ៣០ ថ្ងៃសំរាប់ឃ្លាំង និង ទីលានបញ្ចេញទំនិញពីគយដែលស្ថិតនៅព្រលានយន្តហោះ
- ៤៥ ថ្ងៃសំរាប់ឃ្លាំងនិងទីលានបញ្ចេញទំនិញពីគយដែលស្ថិតនៅកន្លែងក្រៅពីព្រលានយន្តហោះ ។ រយៈកាលនេះត្រូវគិតពីថ្ងៃចុះបញ្ជីកាប្រតិទេវន៍បំព្រួញ ។

**ប្រការ ២.~** ក្រោយពីថ្ងៃដែលបានកំណត់ដូចមានក្នុង ប្រការ១ ខាងលើ ទំនិញទាំងឡាយត្រូវដាក់ជា ស្វ័យប្រវត្តិក្នុងនិក្ខិត្តភ័ណ្ឌគយ (dépôt de douane) កាលបើទំនិញទាំងនោះពុំបានធ្វើប្រតិវេទន៍លំអិតនោះទេ ។ ក្នុងរយៈពេលដែលទំនិញត្រូវដាក់ក្នុងនិក្ខិត្តភ័ណ្ឌគយ (dépôt de douane) នោះម្ចាស់ទំនិញត្រូវបង់កំរៃ (Redevance de dépôt) ០,១% លើថ្លៃទំនិញ (CIF) ក្នុងមួយថ្ងៃជូនរាជការគយនិងរដ្ឋាករ ។ ប្រាក់កំរៃទាំងនេះត្រូវកត់ត្រាចូលប្រតិវេទន៍លំអិត និង បង់ចូលថវិការដ្ឋតាមនាមវលីថវិកា (nomenclature budgétaire) ១៣.០១.០៣ ។ ទំនិញទាំងឡាយដែលត្រូវដឹកលំជានិក្ខិត្តភ័ណ្ឌគយនោះត្រូវកត់ត្រាចុះក្នុងបញ្ជីពិសេស ។

**ប្រការ ៣.**~ ទំនិញទាំងឡាយដែលគេពុំបានយកចេញក្នុងរយៈពេល ៣ ខែ គិតតាំងពីថ្ងៃកត់ចូលក្នុង បញ្ជីនៃនិក្ខិត្តភ័ណ្ឌគយ ត្រូវដាក់លក់ឡាយឡុងជាសាធារណៈក្រោយមានការអនុញ្ញាតពីតុលាការ ។

–ទំនិញទាំងឡាយដែលឆាប់ខូច ឬ ទុកពុំបានយូរ អាចលក់បានមួយរំពេចដោយមានការអនុញ្ញាតពីតុលាការ

–ទំនិញទាំងឡាយដែលមានតំលៃតិចជាង ១០០.០០០ រៀល ដែលគេពុំបានយកចេញនៅពេលផុតរយៈវេលា ០៣ ខែ ដូចមានចង្អុលនៅក្នុងកថាខ័ណ្ឌទី១ ខាងលើត្រូវចាត់ ទុកជាគេបោះបង់ចោល ។ រាជការគយនិងរដ្ឋាករអាចដាក់លក់ឡាយឡុងបាន ឬ ធ្វើជា អំណោយដល់មន្ទីរពេទ្យ សង្គហដ្ឋាន (hospices) ឬគ្រឹះស្ថានសប្បុរសធម៌ឯទៀតបាន ។

**ប្រការ ៤.**~ រាជការគយនិងរដ្ឋាករជាអ្នកចាត់ចែងតាមការលក់ដេញថ្លៃជាសាធារណៈ និងដល់អ្នកហ៊ានអោយថ្លៃជាងគេក្រោយបំផុត ។ ទំនិញទាំងឡាយដែលដាក់លក់ត្រូវបានអោយរួចពន្ធ និង អាករដែលភ្នាក់ងារនិងរដ្ឋាករត្រូវហូតយក ។ អ្នកដេញបានមានសិទ្ធិចាត់ចែង ទំនិញនោះតាមគម្យស្ថាន (destination)ដែលច្បាប់និងបទបញ្ជាជាធរមានបានអនុញ្ញាតអោយ ។

**ប្រការ ៥.**~ ផលពីការលក់ត្រូវយកទៅចាត់ចែងសងរហូតដល់គ្រប់ប្រាក់ជំពាក់តាមលំដាប់អាទិភាពដូចតទៅ ÷

ក–កាត់សងសោហ៊ុយ និងចំណាយបន្ទាប់បន្សំគ្រប់ប្រភេទទាំងឡាយដែលភ្នាក់ងារនិងរដ្ឋាករបានចេញចាយក្នុងការតម្កល់និងការសំចតអោយនៅជានិក្ខិត្តភ័ណ្ឌព្រមទាំងការលក់ទំនិញទាំងនេះ ។

ខ–បង់ពន្ធនិងអាករដែលទំនិញទាំងឡាយត្រូវជាប់តាមគម្យដ្ឋាន ។

គ–ការកាត់សងប្រាក់កំរៃសោហ៊ុយដទៃទៀតដែលត្រូវចំណាយលើទំនិញ ។

–សំណល់ពីនេះត្រូវដាក់ទៅក្នុងបេឡានៃនិក្ខិត្តភ័ណ្ឌនិងបញ្ជីត្រូវទុក២ឆ្នាំដើម្បីរង់ចាំម្ចាស់ទំនិញ ឬ សិទ្ធិលាភទាំងឡាយ ។ ដល់ផុតរយៈវេលានេះ ត្រូវបានជាគុណប្រយោជន៍ដល់ថវិការដ្ឋ ។ ក៏ប៉ុន្តែកាលបើទំនិញដែលដាក់លក់

បានមិនលើសពី ១០០.០០០ រៀលទេ ប្រាក់សំណល់ត្រូវដាក់ជាចំណូល នៃថវិកាភ្នាម ។

**ប្រការ ៦.**- ទំនិញទាំងឡាយដែលបាននាំចូលមុនថ្ងៃអនុវត្តប្រកាសនេះដែលកំពុងស្ថិតនៅក្នុងឃ្លាំងនោះក៏ត្រូវទទួលបន្ទុកអនុវត្តដូចប្រកាសនេះផងដែរ ។

**ប្រការ ៧.**- បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៨.**- ប្រកាសនេះអោយមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃទី ០១ ខែ សីហា ឆ្នាំ ១៩៩៦ តទៅ ។

ហត្ថលេខា និង ត្រា

**គាត ឈន់**

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ១៩៩៦

**ប្រកាស លេខ : ២៥៨ ប្រក.សហវ.គរ**

**ស្តីពីការគ្រប់គ្រងប្រមូលពន្ធលើទំនិញនាំចេញ និង នាំចូលតាមកុងតឺន័រ « CONTAINER » ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ការិយាល័យគ្រប់គ្រងផែស្ងួតនិងឃ្លាំងដែលគ្រប់គ្រងដោយគយនិងទីលានបញ្ចេញទំនិញពីគយ និង រដ្ឋាករ**

* * *

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល